ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

លេខៈ ៥ ឆ្នាំ២០១៥

# របាយការណ៍សវនកម្ម

# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការិយបរិច្ឆេទ ២០០៩

# អារម្ភកថា

ឆ្នាំ២០០៩ គឺជាឆ្នាំដំបូងនៃការអនុវត្ត "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បច្ចុប្បន្នកម្ម ២០០៩-២០១៣" ដែលជាត្រីវិស័យក្នុងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច និង"យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព-ដំណាក់កាលទី២" ដែលជា "របៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភា"។ ឆ្នាំ២០០៩ ក៏ជាឆ្នាំចាប់ផ្តើមអនុវត្ត "កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២" ផងដែរ។ ព្រមជាមួយនោះ ក៏ជាឆ្នាំដែលកម្ពុជាកំពុងបន្តក្រេបជញ្ជក់នូវសន្តិភាពពេញលេញ ឯកភាពទឹកដីទាំងស្រុង ដែលកើតចេញឡើងកាលពី១២ឆ្នាំមុននេះពី "នយោបាយឈ្នះ-ឈ្នះ" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

សម្តេចតេជោ បានមានប្រសាសន៍នៅក្នុងវេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ (CDCF) នាថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ ថា "ឆ្នាំ២០០៩ គឺជាឆ្នាំដ៏លំបាកសម្រាប់កម្ពុជា។ កលិយុគហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលលោកបានបង្កហានិភ័យ ដែលគំរាមដល់សមិទ្ធផលជាផ្លែផ្កានៃការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ដែលយើងសម្រេចបានក្នុងរយៈពេលកន្លងមក"។ ជាភ័ព្វសំណាងរបស់ព្រះរាជាណាចក្រកម្ពុជា ដែលមានអគ្គមគ្គុទ្ទេសន៍ដ៏ឆ្នើមគឺ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានឆន្ទៈមោះមុត ឧត្តមគតិខ្ពង់ខ្ពស់ គិតគូរបានគ្រប់ជ្រុងជ្រោយច្បាស់លាស់ បានឆ្លើយតបនឹង

បញ្ហាប្រឈមទាំងនោះទាន់ពេលវេលាដោយបានដាក់ចេញ និងអនុវត្តនូវវិធានការ គោលនយោបាយគន្លឹះៗ ដើម្បីទប់ទល់ និងសម្រាលនូវបច្ច័យអាក្រក់ដែលបណ្តាលមកពីវិបត្តិទាំងនេះ ដោយខិតខំជំនះផលវិបាកអាក្រក់ទាំងនេះ តាមរយៈការប្រឹងប្រែងក្តាប់ឱ្យបាននូវជីពចរសេដ្ឋកិច្ចជាតិ និងធានាឱ្យបាននូវបរិស្ថានម៉ាក្រូសេដ្ឋកិច្ចមួយដែលមានលក្ខណៈគត់មត់ មានភាពអំណោយផលសម្រាប់សេដ្ឋកិច្ច និងពិសេសបំផុតគឺធានានូវលំនឹងនៃជីវភាពប្រចាំថ្ងៃរបស់ប្រជាជន។

ជាសក្ខីភាពឆ្លុះបញ្ចាំងឱ្យឃើញពីភាពជោគជ័យនៃកំណើនសេដ្ឋកិច្ចជាវិជ្ជមាន ពិតមែនតែវាតិចតួច(០,១%) ទោះបីប្រទេសកម្ពុជារងនូវផលប៉ះពាល់អាក្រក់ដែលបណ្តាលមកពីវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ ការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក និងស្ថិតក្នុងស្ថានភាពដែលព្រះរាជាណាចក្រកម្ពុជា ត្រូវពង្រឹងមូលដ្ឋានសម្រាប់ការពារខឿនអធិបតេយ្យភាព និងបូរណភាពទឹកដីយ៉ាងណាក៏ដោយ។ លទ្ធផលនេះបាននាំមកនូវការកាត់បន្ថយភាពក្រីក្របានជាង១% ក្នុងឆ្នាំ២០០៩។ **អត្រានៃភាពក្រីក្រ បានធ្លាក់ចុះពី ៣០,៧% នៅឆ្នាំ២០០៧ មក ២៧,៥% នៅឆ្នាំ២០០៩។**

ដើម្បីចូលរួមចំណែកសម្រេចគោលដៅរបស់រាជរដ្ឋាភិបាលខាងលើនេះ អាជ្ញាធរសវនកម្មជាតិបានចូលរួមក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយតម្លាភាព គណនេយ្យភាព និងឈានទៅរកអភិបាលកិច្ចល្អតាមរយៈការផ្តល់អនុសាសន៍ និងការធ្វើសវនកម្មនៅអង្គភាពរងសវនកម្ម។ របាយការណ៍សវនកម្មលេខ៥នេះ អាជ្ញាធរសវនកម្មជាតិនឹងផ្សព្វផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រង

ហិរញ្ញវត្ថុសាធារណៈ ដែលលើកឡើងដោយសង្ខេបនូវលទ្ធផលនៃការធ្វើសវនកម្មលើការអនុវត្តការងារក្នុងការិយបរិច្ឆេទ២០០៩ របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធមួយចំនួន។

ទន្ទឹមនឹងនេះ អាជ្ញាធរសវនកម្មជាតិកំពុងបន្តខិតខំពង្រឹងសមត្ថភាពសវនករ និងបង្កើនគុណភាពសវនកម្មឱ្យឆ្លើយតបទៅនឹងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ស្របទៅតាមស្តង់ដារវិជ្ជាជីវៈសវនកម្មរបស់អង្គការអាស៊ីនៃស្ថាប័នសវនកម្មកំពូល (ASOSAI) និងអង្គការអន្តរជាតិនៃស្ថាប័នសវនកម្មកំពូល (INTOSAI) ដោយកំពុងអនុវត្តនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍឆ្នាំ២០០៧-២០១១ ដើម្បីសម្រេចនូវចក្ខុវិស័យ គោលដៅ និងបេសកកម្មរបស់អាជ្ញាធរសវនកម្មជាតិ ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណ និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាលដែលជានិច្ចជាកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិទាំងក្នុងក្របខ័ណ្ឌច្បាប់ ក៏ដូចជាក្របខ័ណ្ឌហិរញ្ញវត្ថុ សម្ភារ និងស្មារតី។

ព្រមជាមួយនេះ សូមថ្លែងអំណរគុណផងដែរដល់អង្គការកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ (GIZ) ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ធនាគារពិភពលោក(World Bank) អង្គការ DANIDAនៃប្រទេសដាណឺម៉ាក ព្រមទាំងដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានា ដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ស្ថាប័ន។

ទន្ទឹមនឹងនេះ ក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបានស្នាដៃគួរកត់សម្គាល់។ ជាមួយនេះផងដែរ ខ្ញុំថ្លែងអំណរគុណចំពោះគ្រប់អង្គភាពរងសវនកម្ម និងសាធារណជនដែលបានសហការយ៉ាងជិតស្និទ្ធ ផ្តល់ការគាំទ្រលើកទឹកចិត្តដល់អាជ្ញាធរសវនកម្មជាតិ ឱ្យបំពេញភារកិច្ចរបស់ខ្លួនសម្រេចបានជោគជ័យគួរឱ្យកត់សម្គាល់។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥

**អគ្គសវនករ**

**សោម គឹមសួគ៌**

# មាតិកា


**សេចក្តីសង្ខេប** .......... ១

**១. សេចក្តីផ្តើម** .......... ៤

**១.១.លក្ខណៈទូទៅ** .......... ៤

**១.២. ការអនុវត្ត និងដែនកំណត់សមធនកម្ម** .......... ៥

**១.៣. គោលបំណងនៃការផ្សព្វផ្សាយ** .......... ៦

**២. ការគ្រប់គ្រងថវិកា** .......... ៦

**២.១.មូលដ្ឋានគតិយុត្តិនៃការអនុវត្តថវិកា** .......... ៦

**២.២.កិច្ចប្រតិបត្តិការថវិកា** .......... ៨

**៣. លទ្ធផលសមធនកម្ម** .......... ៩

**៣.១.ការគ្រប់គ្រងថវិកាទូទៅរបស់រដ្ឋ** .......... ៩

៣.១.១. ការគ្រប់គ្រងក្រុមហ៊ុនសេវាកម្មវាយតម្លៃ និង សេវាកម្មអចលនវត្ថុ .......... ៩

៣.១.២. ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន .. ១១

៣.១.៣. ក្រុមហ៊ុន និងអាជីវកម្មដ្ឋានប្រើប្រាស់អាជ្ញាប័ណ្ណ ទេសចរណ៍ហួសសុពលភាព .......... ១៣

៣.១.៤. ការគ្រប់គ្រងអាជ្ញាប័ណ្ណទេសចរណ៍ .......... ១៥

៣.១.៥. លក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ ...... ១៦

៣.១.៦. ការត្រួតពិនិត្យភាពប្រាកដប្រជានៃចំណាយ ថវិការដ្ឋ .......... ១៨

៣.១.៧. ការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ.......... ២០

៣.១.៨. ការវាយតម្លៃលើប្រភពធនធានទ្រព្យសម្បត្តិរដ្ឋ .. ២១

៣.១.៩. ការអនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈ .......... ២២

**៣.២. ការគ្រប់គ្រងថវិការរបស់រាជធានី ខេត្ត**..................២៣

៣.២.១. ការគ្រប់គ្រង និងការប្រមូលចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូន ......................................២៣

៣.២.២. ការប្រមូលចំណូលពីសត្តឃាតដ្ឋាន .................. ២៥

៣.២.៣. ចំណាត់ការលើការសាងសង់........................... ២៦

៣.២.៤. ការគ្រប់គ្រងប្រើប្រាស់ប័ណ្ណភាស៊ី.....................២៧

**៣.៣. ការអនុវត្តគម្រោងវិនិយោគ** ................................ ២៨

៣.៣.១. ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ...................... ២៨

**៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម** ....................................................................៣០

**៥. សេចក្តីសន្និដ្ឋាន**................................................................៣៨

# របាយការណ៍សវនកម្ម
# លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់
# ការិយបរិច្ឆេទ២០០៩

## សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈមួយ ដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។

ឆ្នាំ២០០៩ ព្រះរាជាណាចក្រកម្ពុជានៅតែទទួលរងនូវផលប៉ះពាល់អាក្រក់បំផុត ពីវិបត្តិកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក ព្រមទាំងបន្ថែមបន្ទុកធ្ងន់ធ្ងរពីកិច្ចការពារអធិបតេយ្យភាព និងបូរណភាពទឹកដី។ ប៉ុន្តែដោយមានការដឹកនាំប្រកបដោយភាពឈ្លាសវៃ មានឆន្ទៈមោះមុតប្រកបដោយឧត្តមគតិ និងគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា បានជំនះពុះពារឆ្លងផុតឧបសគ្គទាំងនោះ។ ជាសក្ខីភាព រាជរដ្ឋាភិបាលកម្ពុជានៅតែរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម ធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចដែលមានលក្ខណៈគត់មត់ **ធ្វើឱ្យសេដ្ឋកិច្ចមានកំណើនជាវិជ្ជមាន** កាត់បន្ថយបាននូវអត្រាភាពក្រីក្រជាង **១%** ក្នុងមួយឆ្នាំ។ អត្រានៃភាពក្រីក្របានធ្លាក់ចុះពី**៣០,៧%** នៅឆ្នាំ**២០០៧** មក **២៧,៥%** នៅឆ្នាំ**២០០៩**។

ក្នុងការិយបរិច្ឆេទ២០០៩ អាជ្ញាធរសវនកម្មជាតិ បានធ្វើសវនកម្មលើបណ្ដាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួន ដូចមានលទ្ធផលសង្ខេបបង្ហាញខាងក្រោម ៖

ការអនុវត្តចំណូលតាមរយៈរតនាគារជាតិក្នុងឆ្នាំសម្រេចបានចំនួន ៥.២៤៣.២៨៦លានរៀល ស្មើនឹង ៩៥,៩% នៃផែនការឆ្នាំដែលមានចំនួន ៥.៤៦៩.៥៦៦លានរៀល។ តាមរយៈការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា នៅមានសក្ដានុពលដែលចាំបាច់ត្រូវពង្រឹង និងធ្វើឱ្យប្រសើរឡើងថែមទៀតដូចជា ៖

- ជំរុញការផ្ទេរចំណូលពន្ធគយចូលថវិកា ជំរុញការដោះស្រាយទំនិញគ្មានការទាមទារ បន្តពង្រឹងការតាមដានការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធ បន្តពង្រឹងវិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញ និងបន្តពង្រឹងការត្រួតពិនិត្យឯកសារនាំចូលទំនិញគ្មានលក្ខណៈពាណិជ្ជកម្ម។
- ពង្រឹងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន បន្តពង្រឹងការប្រកាសពន្ធរបស់ក្រុមហ៊ុន-សហគ្រាស ជំរុញកិច្ចសហការផ្លាស់ប្ដូរព័ត៌មានជាមួយក្រសួង-ស្ថាប័ន ការបង់ពន្ធអាករលើតម្លៃបន្ថែម ជំរុញការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងជំរុញភាពសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ព្រមទាំងខិតខំប្រមូលបំណុលពន្ធដែលនៅជំពាក់។

- ពង្រឹងការផាកពិន័យចំពោះក្រុមហ៊ុនសេវាវាយតម្លៃ និងសេវាអចលនទ្រព្យ ពង្រឹងការគ្រប់គ្រងអាជីវកម្មដឹកជញ្ជូន ពង្រឹងការគ្រប់គ្រងអាជីវកម្មទេសចរណ៍ ពង្រឹងការគ្រប់គ្រងចំណូលពីសត្តឃាតដ្ឋាន និងភាសុី ព្រមទាំងខិតខំប្រមូលនូវបំណុលមិនមែនសារពើពន្ធដែលនៅសល់មិនទាន់សង។

ការអនុវត្តចំណាយតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិក្នុងឆ្នាំ ២០០៩ សម្រេចបានចំនួន ៥.៩៧៦.៩៩៨លានរៀល ស្មើនឹង **១០៣,១%** នៃផែនការដែលមានចំនួន៥.៧៩៦.៩៩៩លានរៀល។ ក្នុងការអនុវត្តចំណាយថវិកានេះ មានចំណុចគួរឱ្យកត់សម្គាល់មួយចំនួនជាអាទិ៍ ការបន្តពង្រឹងការអនុវត្តនីតិវិធី និងវិធីសាស្ត្រលទ្ធកម្មសាធារណៈ នៅបន្តមានការបញ្ជូនអាណត្តិបើកប្រាក់យ៉ាងគំហុកទៅឱ្យអគ្គនាយកដ្ឋានរតនាគារជាតិនៅចុងឆ្នាំ និងក្រោយថ្ងៃនិសានភាពបិទបញ្ជី ការជំរះទូទាត់ថវិកាបុរេប្រទានមិនទាន់ពេលនៅតែមាន ការដកចំណូលយកទៅចំណាយមុនបង់ចូលថវិការដ្ឋ និងការត្រួតពិនិត្យទៅលើការចំណាយថវិការដ្ឋនៅមានកម្រិត។

ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមានចំណុចគួរឱ្យកត់សម្គាល់ដូចជា ត្រូវបន្តពង្រឹងការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងបន្តពង្រឹងការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋឱ្យបានទាន់ពេលវេលា។

ការអនុវត្តកិច្ចបញ្ជីកាបំណុលគួរតែប្រមូលផ្តុំនៅរតនាគារជាតិ ដើម្បីងាយស្រួលតាមដាន និងត្រួតពិនិត្យឱ្យបានច្បាស់លាស់។

## ១. សេចក្តីផ្តើម

### ១.១. លក្ខណៈទូទៅ

ឆ្នាំ២០០៩ ប្រទេសកម្ពុជាទទួលរងនូវផលប៉ះពាល់មុខព្រួញជាច្រើនក្នុងពេលតែមួយជាមួយគ្នា ហេតុដូច្នេះ ការគ្រប់គ្រងចាត់ចែងថវិកាទូទៅរបស់រដ្ឋមិនមានភាពងាយស្រួលទេ ទាមទារត្រូវមានភាពឈ្លាសវៃ ភាពប៉ិនប្រសប់ ទើបជំនះផុតពីហានិភ័យទាំងនេះ។ ចូលរួមចំណែកជាសក្ខីភាពនៃការបញ្ជាក់នូវប្រសិទ្ធភាពនៃការអនុវត្តច្បាប់ថវិកាសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ សម្រាប់ការគ្រប់គ្រងការិយបរិច្ឆេទ២០០៩។ របាយការណ៍ទាំងនេះត្រូវបានធ្វើជូនរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងធ្វើការផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់តាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ ការផ្សព្វផ្សាយរបាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ គឺសង្ខេបលទ្ធផលនៃការធ្វើសវនកម្ម ដែលអាជ្ញាធរសវនកម្មជាតិបានអនុវត្តសម្រាប់ការិយបរិច្ឆេទ២០០៩។

ការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិ រួមមានការធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនី ប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួង ស្ថាប័ន ភ្នាក់ងារអាជ្ញាធរ ធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុរដ្ឋចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានី ខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកម៉ៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការ

ផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀត អង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជនទៀតផង។

## ១.២. ការអនុវត្ត និងវិធានកំណត់សវនកម្ម

ចាប់តាំងពីដំណើរការការងារនៅចុងឆ្នាំ២០០១ រហូតដល់ឆ្នាំ២០០៩ អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ និងបានធ្វើរបាយការណ៍សរុបចំនួន **៤៥៩** របាយការណ៍។ ដោយឡែកសម្រាប់ការិយបរិច្ឆេទ**២០០៩** អាជ្ញាធរសវនកម្មជាតិ បានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សវនកម្មបានចំនួន**៨២** ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ត្រូវបានដកស្រង់យកមកបង្ហាញក្នុងចំណុច៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារនៃការធ្វើសវនកម្មទូទៅ ដែលតម្រូវឱ្យមានការរៀបចំផែនការសវនកម្ម និងអនុវត្តការងារសវនកម្ម ដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង លើការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបាននូវភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើការសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្ម។

### ១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតផ្សេងៗ ដែលបានអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អសំដៅធ្វើឱ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងប្រព័ន្ធគ្រប់គ្រងរបស់ក្រសួង ស្ថាប័នមានភាពកាន់តែប្រសើរ និងឈានទៅរកអភិបាលកិច្ចល្អ។

អាជ្ញាធរសវនកម្មជាតិ អនុវត្តកាតព្វកិច្ចផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ ដោយអនុលោមតាមមាត្រា២៩ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងពេលដែលមានតតិយជនទាំងឡាយណា យកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈ ទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅជាយថាហេតុ។

## ២.ការគ្រប់គ្រងថវិកា

### ២.១. មូលដ្ឋានគតិយុត្តិនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃការអនុវត្តថវិកាសម្រាប់ឆ្នាំ២០០៩នេះ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធ មានជាអាទិ៍ ៖

- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ត្រូវបាន ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨។
- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវបានប្រកាសឱ្យ ប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានប្រកាសឱ្យប្រើ ដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៩ ត្រូវបាន ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៨។
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យ សាធារណៈ។
- អនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ២.២.កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋឆ្នាំ២០០៩ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូល ចំណាយតាមរយៈរតនាគារជាតិ និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០០៨ | ២០០៩ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3* | *4 = (3/2)* |
| I. សរុបចំណូល | **7.500.141** | **7.259.566** | **7.995.426** | **110,1%** |
| - ចំណូលចរន្ត | 5.213.163 | 5.086.566 | 4.898.896 | 96,3% |
| - ចំណូលមូលធនក្នុងប្រទេស | 79.208 | 48.000 | 29.284 | 61,0% |
| - មូលនិធិទ្រទ្រង់ថវិកា | 281.577 | 335.000 | 315.106 | 94,1% |
| - ប្រើប្រាស់ប្រាក់បញ្ញើរាជរដ្ឋាភិបាល | - | 90.000 | - | - |
| - ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 1.926.193 | 1.700.000 | 2.752.140 | 161,9% |

*ឯកតា : លានរៀល*

| បរិយាយ | អនុវត្ត ២០០៨ | ២០០៩ | | |
|---|---|---|---|---|
| | | ច្បាប់ហិរញ្ញវត្ថុ | អនុវត្ត | ភាគរយ |
| | *1* | *2* | *3* | *4=(3/2)* |
| **II. សរុបចំណាយ** | **6.513.908** | **7.496.944** | **8.729.088** | **116,4%** |
| - ចំណាយចរន្ត | 3.774.115 | 4.526.444 | 4.756.757 | 105,1% |
| - ចំណាយមូលធន | 813.600 | 1.270.500 | 1.220.191 | 96,0% |
| - ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស | 1.926.193 | 1.700.000 | 2.752.140 | 161,9% |

## ៣.លទ្ធផលសមិទ្ធកម្ម

### ៣.១.ការគ្រប់គ្រងថវិកាឆ្លងទៅរបស់រដ្ឋ

#### ៣.១.១.ការគ្រប់គ្រងក្រុមហ៊ុនសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ

ដើម្បីគ្រប់គ្រងក្រុមហ៊ុនសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់ដល់ក្រុមហ៊ុនដែលប្រកបអាជីវកម្មនេះនូវវិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ ដោយកំណត់ឱ្យក្រុមហ៊ុនផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងប្រចាំខែមកក្រសួង។ ប្រកាសលេខ១៤២ សហវ/ប្រក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការផ្តល់វិញ្ញាបនប័ត្រ និងអាជ្ញាប័ណ្ណផ្នែកសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ ត្រង់ប្រការ១៣ បានចែងថា "ការយឺតយ៉ាវក្នុងការផ្តល់របាយការណ៍ប្រចាំខែ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមការ

កំណត់ត្រូវផាកពិន័យដូចមានចែងក្នុងសៀវភៅបន្ទុក។ សៀវភៅបន្ទុកសម្រាប់អ្នកកាន់អាជ្ញាប័ណ្ណសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ ត្រង់ប្រការ ១០ ចែងថា៖ក្នុងករណីមានការយឺតយ៉ាវការផ្តល់របាយការណ៍ប្រចាំខែ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដូចមានចែងក្នុងប្រការ ១២ និងប្រការ១៣ នៃសៀវភៅបន្ទុកនេះ ត្រូវផាកពិន័យជាទឹកប្រាក់ចំនួន ១.០០០.០០០រៀល។ ក្នុងឆ្នាំ ២០០៩ មានក្រុមហ៊ុនសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ ចំនួន១០ ក្នុងចំណោម៣២ មិនបានផ្តល់របាយការណ៍ប្រចាំខែ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក៏ពុំមានធ្វើការផាកពិន័យលើក្រុមហ៊ុនទាំងនោះឡើយ។

ការមិនបានអនុវត្តពេញលេញនូវប្រកាសលេខ១៩២ និងសៀវភៅបន្ទុក ជាហេតុនាំឱ្យបន្ថយចំណូលថវិកា។ អាស្រ័យហេតុនេះ អាជ្ញាធរសវនកម្មជាតិសូមឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជំរុញដល់ក្រុមហ៊ុនឱ្យគោរពច្បាប់ និងអនុវត្តយ៉ាងពេញលេញនូវប្រកាស ព្រមទាំងលក្ខខណ្ឌដែលមានចែងក្នុងសៀវភៅបន្ទុក។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបំភ្លឺថា វិបត្តិហិរញ្ញវត្ថុសកលដែលបានអូសបន្លាយពីចុងឆ្នាំ២០០៧ រហូតមកដល់២០០៩ បានជះឥទ្ធិពលលើវិស័យអចលនវត្ថុនៅកម្ពុជា។ កត្តានេះបានធ្វើឱ្យក្រុមហ៊ុនសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុស្ទើរតែទាំងអស់ត្រូវផ្អាកសកម្មភាពអាជីវកម្មរបស់ខ្លួនទាំងស្រុង ដែលជាហេតុធ្វើឱ្យក្រុមហ៊ុនស្របច្បាប់ខ្លះមិនបានផ្តល់របាយការណ៍ប្រចាំខែ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួន តាមការតម្រូវរបស់ក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងខ្លះទៀតមិនបានមកបន្តសុពលភាពអាជ្ញាប័ណ្ណថែមទៀតផង។ ដើម្បីជួយសម្រាលបន្ទុកខ្លះដល់វិស័យអចលនវត្ថុ ដែលកំពុងស្ថិតក្នុងស្ថានភាពជុនដាបនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំទាន់ផាកពិន័យក្រុមហ៊ុនសេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុឡើយ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនឹងធ្វើការពិនិត្យនូវវឌ្ឍនភាពជាបន្តទៀត។

## ៣.១.២. ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូន

ក្រសួងសាធារណការ និងដឹកជញ្ជូន បានចេញសារាចរណែនាំលេខ០០១ សរសក.ដជ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការអនុវត្តកាតព្វកិច្ចធានារ៉ាប់រងទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន និងកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ បានបញ្ជាក់ថា "...ក្នុងករណីដែលម្ចាស់យានយន្ត ឬអ្នកបើកបរមិនបានទិញប័ណ្ណធានារ៉ាប់រង ក្រសួងអាចចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនឱ្យប្រើប្រាស់ជាបណ្តោះអាសន្ន ប៉ុន្តែក្រោយរយៈពេល៦០ថ្ងៃ នៃការចេញលិខិតធ្វើអាជីវកម្មរួចមក ម្ចាស់យានយន្ត ឬអ្នកបើកបរនៅតែមិនព្រមបំពេញកាតព្វកិច្ចធានារ៉ាប់រង ក្រសួងក៏អាចដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម..."។ ក្នុងឆ្នាំ២០០៩ អង្គភាពក្រោមឱវាទរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនមួយចំនួន បានចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មដឹកជញ្ជូនដល់ម្ចាស់យានយន្ត ឬអ្នកបើកបរពុំមានភ្ជាប់ប័ណ្ណធានារ៉ាប់រងថតចម្លងទេ។ លើសពីនេះទៅទៀត អង្គភាពទាំងនោះពុំមានវិធានការដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម

ទៅលើរថយន្តមួយចំនួន ខណៈដែលម្ចាស់យានយន្តមិនព្រម បំពេញកាតព្វកិច្ចធានារ៉ាប់រងក្រោយរយៈពេល ៦០ថ្ងៃបន្ទាប់ពី បានទទួលលិខិតអនុញ្ញាតធ្វើអាជីវកម្ម ។

ក្នុងករណីនេះ ដើម្បីបង្ការហានិភ័យលើការដឹកជញ្ជូន ជាយថាហេតុ ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថាប័ន ពាក់ព័ន្ធ គួរធ្វើការសហការអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ ទាំងឡាយដែលពាក់ព័ន្ធនឹងការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម ដឹកជញ្ជូន និងមានវិធានការម៉ឺងម៉ាត់ចំពោះអាជីវករណា ដែល មិនបំពេញកាតព្វកិច្ច ធានារ៉ាប់រង។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសាធារណ ការ និងដឹកជញ្ជូនបានបំភ្លឺថា ចំពោះសំណុំឯកសារដែលមាន ភ្ជាប់នូវប័ណ្ណធានារ៉ាប់រង គឺជាយានយន្តរបស់បណ្តាក្រុមហ៊ុន ដែលមានលទ្ធភាពអនុវត្តការបង់ធានារ៉ាប់រង ឯអតិថិជនមួយ ចំនួនជាប្រជាពលរដ្ឋដែលមានយានយន្តធ្វើអាជីវកម្មជាលក្ខណៈ គ្រួសារពុំអាចមានលទ្ធភាពបង់ធានារ៉ាប់រង ដោយចំណូល របស់គាត់បានត្រឹមតែសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារប៉ុណ្ណោះ។ ម្យ៉ាងទៀតនៅតាមបណ្តាខេត្តពុំមានក្រុមហ៊ុនធានារ៉ាប់រងបោះ ទីតាំង។ ចំពោះការដកហូតលិខិតអនុញ្ញាតអាជីវកម្មដឹកជញ្ជូន ផ្លូវគោកបណ្តោះអាសន្ន អគ្គនាយកដ្ឋានដឹកជញ្ជូន មន្ទីរ សាធារណការ និងដឹកជញ្ជូនរាជធានីភ្នំពេញ ខេត្តកណ្តាល បាត់ដំបង បន្ទាយមានជ័យ និងខេត្តកំពង់ចាម ពាក់ព័ន្ធទាំងនោះ ពុំមានលទ្ធភាពធ្វើការហាមឃាត់រថយន្តដែលកំពុងធ្វើចរាចរ នោះទេ។ ក្នុងបញ្ហានេះជាភារកិច្ចរបស់នគរបាល ក្រសួងនឹង ស្នើសុំអន្តរាគមន៍ពីក្រសួងមហាផ្ទៃដើម្បីដោះស្រាយ និង

សហការខ្ពស់ក្នុងរឿងនេះ។ ចំពោះករណីនេះ ក្រសួងសាធារណការ និងដឹកជញ្ជូនទទួលយកអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិនៅតែសំណូមពរឱ្យអង្គភាពពាក់ព័ន្ធ គួរអនុវត្តឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិទាំងឡាយ ដែលពាក់ព័ន្ធនឹងការចេញលិខិតអនុញ្ញាតដឹកជញ្ជូន និងមានវិធានការម៉ឺងម៉ាត់ចំពោះម្ចាស់យានយន្តណាដែលមិនបំពេញកាតព្វកិច្ចធានារ៉ាប់រង។

## ៣.១.៣.ក្រុមហ៊ុន និងអាជីវកម្មដ្ឋានប្រើប្រាស់អាជ្ញាប័ណ្ណទេសចរណ៍ហួសសុពលភាព

ប្រកាសលេខ០៦១ ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងទេសចរណ៍ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់អាជីវកម្មទីភ្នាក់ងារទេសចរណ៍ បានកំណត់ថាការប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ឬអនុវត្តមិនបានត្រឹមត្រូវតាមការណែនាំរបស់ក្រសួងទេសចរណ៍ អាជីវករនឹងត្រូវទទួលនូវការផាកពិន័យចំនួនទឹកប្រាក់២០០% (ពីររយភាគរយ) នៃថ្លៃបង់ឆ្នាំដំបូង។ ប្រសិនបើអាជីវករមិនបង់ប្រាក់ផាកពិន័យនេះ ក្នុងរយៈពេល០៣ខែ ក្រសួងទេសចរណ៍នឹងផ្អាកការធ្វើអាជីវកម្ម ឬដកហូតអាជ្ញាប័ណ្ណទេសចរណ៍ ដោយមិនអនុញ្ញាតឱ្យប្រកបអាជីវកម្មទៀតឡើយ។ ក្នុងឆ្នាំ២០០៩ មានក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ និងអាជីវកម្មដ្ឋានដែលប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ចំនួន១០២ ទីតាំង ក្នុងនោះក្រសួងបានធ្វើការផាកពិន័យតែចំនួន៧ ទីតាំង រីឯចំនួន៩៥ ទីតាំងទៀតពុំបានធ្វើការផាកពិន័យ។

ការមិនបានធ្វើការផាកពិន័យធ្វើឱ្យបាត់បង់ចំណូលថវិកាជាតិ។ ដោយហេតុនេះ ក្រសួងទេសចរណ៍ត្រូវធ្វើការណែនាំអង្គភាពក្រោមឱវាទឱ្យធ្វើការផាកពិន័យចំពោះក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ និងអាជីវកម្មដ្ឋានដែលប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាពឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាស។

ឆ្លើយតបនឹងការលើកឡើងខាងលើ ក្រសួងទេសចរណ៍បានបញ្ជាក់ថា ក្នុងករណីនេះ ក្រោយពីច្បាប់ស្តីពីទេសចរណ៍ត្រូវបានប្រកាសឱ្យប្រើប្រាស់រួចមក ក្រសួងទេសចរណ៍បាន និងកំពុងរៀបចំកែសម្រួលរាល់ប្រកាស និងសារាចរណែនាំនានា សំដៅពង្រឹងការគ្រប់គ្រងមូលដ្ឋានអាជីវកម្មទេសចរណ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះអាជីវកម្មដ្ឋានប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព ក្រសួងទេសចរណ៍ និងមន្ទីរទេសចរណ៍រាជធានី-ខេត្ត បានខិតខំប្រឹងប្រែងជំរុញឱ្យមកដាក់ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណទេសចរណ៍ឱ្យបានទាន់ពេលវេលា ដោយទុករយៈពេល២ខែ សម្រាប់រៀបចំបែបបទ (មុនសុពលភាព ១ខែ និងក្រោយសុពលភាព១ខែ)។ ក្រសួងទេសចរណ៍នឹងបន្តជំរុញឱ្យមន្ទីរទេសចរណ៍រាជធានី-ខេត្ត ពង្រឹងការផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍ ព្រមទាំងជំរុញឱ្យប្រតិបត្តិករទេសចរណ៍ទាំងអស់ មកដាក់ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណទេសចរណ៍ ឱ្យបានទាន់ពេលវេលា។ ក្នុងឆ្នាំ២០១១នេះ ក្រោយពីបានកែសម្រួលប្រកាសរួច ក្រសួងទេសចរណ៍នឹងបន្តការផាកពិន័យចំពោះអាជីវកម្ម ដែលប្រើប្រាស់អាជ្ញាប័ណ្ណហួសសុពលភាព។

ផ្អែកតាមការបំភ្លឺខាងលើ ក្រសួងទេសចរណ៍បានឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ដូចនេះអាជ្ញាធរសវនកម្មជាតិនឹងធ្វើការតាមដានការអនុវត្តអនុសាសន៍នេះជាបន្តទៀត។

**៣.១.៤. ការគ្រប់គ្រងអាជ្ញាប័ណ្ណទេសចរណ៍**

ដើម្បីគ្រប់គ្រងអាជីវកម្មទេសចរណ៍ រាជរដ្ឋាភិបាលបានរៀបចំច្បាប់ស្តីពីទេសចរណ៍ ដែលត្រូវបានអនុម័តដោយរដ្ឋសភា ហើយប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៩។ ត្រង់មាត្រា៦៥ នៃច្បាប់នោះបានកំណត់ថា បុគ្គលណាដែលប្រកបអាជីវកម្មទេសចរណ៍ដោយគ្មានអាជ្ញាប័ណ្ណទេសចរណ៍ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ដែលអប្បបរមាស្មើនឹង ២.០០០.០០០រៀល (ពីរលានរៀល) និងអតិបរមាមិនលើសពី ២០.០០០.០០០រៀល (ម្ភៃលានរៀល)។ ទំហំទឹកប្រាក់នៃការពិន័យអន្តរការណ៍សម្រាប់ប្រភេទអាជីវកម្មទេសចរណ៍នីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

ក្នុងឆ្នាំ២០០៩ តាមរបាយការណ៍អាជីវកម្មទេសចរណ៍នៃមន្ទីរទេសចរណ៍ខេត្ត ក្រុង ឃើញមានការធ្វើអាជីវកម្មទេសចរណ៍ដោយគ្មានអាជ្ញាប័ណ្ណចំនួន១៩៣ នៃចំនួនអាជីវកម្មដ្ឋានសរុប១.០៥៧។

ការពុំទាន់បានអនុវត្តតាមច្បាប់ខាងលើ អាចធ្វើឱ្យការគ្រប់គ្រងអាជីវកម្មទេសចរណ៍ពុំទាន់បានល្អប្រសើរ និងអាចបាត់បង់ចំណូលផាកពិន័យចំពោះអាជីវកម្មទេសចរណ៍ដែលគ្មានអាជ្ញាប័ណ្ណ។ អាស្រ័យហេតុនេះ ក្រសួងទេសចរណ៍គួរ

ណែនាំមន្ទីរទេសចរណ៍រាជធានី-ខេត្ត ឱ្យពង្រឹងការផាកពិន័យចំពោះអាជីវកម្មទេសចរណ៍ដែលគ្មានអាជ្ញាប័ណ្ណឱ្យស្របតាមច្បាប់ខាងលើ។

ក្រសួងទេសចរណ៍បានបំភ្លឺថា ក្នុងដំណាក់កាលពុំទាន់មានច្បាប់ស្តីពីទេសចរណ៍ ការចេញអាជ្ញាប័ណ្ណដល់អាជីវកម្មនានាបានធ្វើឡើងដោយក្រសួង ស្ថាប័នពាក់ព័ន្ធជាច្រើន ដូចជា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងពាណិជ្ជកម្ម និងអាជ្ញាធរដែនដីជាដើម។ល។ ក្រសួងបានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍ដល់ម្ចាស់អាជីវកម្មឱ្យមកបំពេញបែបបទដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទេសចរណ៍ ហើយក្រសួងបានកំណត់កាលបរិច្ឆេទមួយ ដើម្បីឱ្យម្ចាស់អាជីវកម្ម ប្រសិនបើលើសកាលកំណត់នឹងប្រឈមការផាក ឬបិទអាជីវកម្ម។ បច្ចុប្បន្នអាជីវកម្មសេវាកម្មទេសចរណ៍ភាគច្រើនបានគោរពច្បាប់ និងមានអាជ្ញាប័ណ្ណទេសចរណ៍ត្រឹមត្រូវ។ ការគ្រប់គ្រងអាជីវកម្មទេសចរណ៍តាមរយៈការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ ទាមទារចាំបាច់នូវពេលវេលាណាមួយសមស្របដើម្បីធ្វើការណែនាំអំពីច្បាប់ទេសចរណ៍ដល់បងប្អូនអាជីវករ ព្រមទាំងការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធខាងលើ ដើម្បីធានាឱ្យយន្តការនៃការគ្រប់គ្រងនេះមិនបង្កើនទម្ងន់ និងបន្ទុកដល់បងប្អូនប្រជាពលរដ្ឋដែលប្រកបអាជីវកម្មតូចតាច។

អាជ្ញាធរសវនកម្មជាតិ នឹងបន្តពិនិត្យនូវវឌ្ឍនភាព។

**៣.១.៥.លក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍**

ប្រកាសលេខ ០៦៣ ប្រក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងទេសចរណ៍ស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់

អាជីវកម្មសណ្ឋាគារ សេវាស្នាក់នៅទេសចរណ៍ គ្រប់ប្រការ៣ បានកំណត់ថា ការរៀបចំសុំអាជ្ញាប័ណ្ណទេសចរណ៍ ឬការសុំបន្តអាជីវកម្ម ត្រូវធ្វើឡើងដោយម្ចាស់ ឬអ្នកគ្រប់គ្រងក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ សណ្ឋាគារ ភោជនីយដ្ឋាន ម៉ាស្សាខារ៉ាអូខេ នាវាទេសចរណ៍ រថយន្តទេសចរណ៍ និងមគ្គុទ្ទេសទេសចរណ៍ និងត្រូវអនុវត្តតាមបែបបទដែលបានកំណត់ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារចាំបាច់ ដូចជាលិខិតអនុញ្ញាតដាក់ទីតាំងធ្វើអាជីវកម្មចេញដោយអាជ្ញាធរដែនដីថ្នាក់ខេត្ត-រាជធានី លិខិតបញ្ជាក់លើប្រព័ន្ធគ្រប់គ្រងអគ្គិសនី និងប្រព័ន្ធការពារសន្តិសុខសុវត្ថិភាព ចេញដោយក្រសួងមហាផ្ទៃ ឬស្នងការនគរបាលខេត្ត-រាជធានី លិខិតបញ្ជាក់អនាម័យចេញដោយក្រសួង ឬមន្ទីរសុខាភិបាល លិខិតចេញដោយក្រសួង ឬមន្ទីរបរិស្ថាន ប័ណ្ណប៉ាតង់ វិញ្ញាបនប័ត្រធានារ៉ាប់រង។ ចំពោះមគ្គុទ្ទេសទេសចរណ៍ត្រូវមានឯកសារចាំបាច់ដូចជាលិខិតថ្កោលទោសពីក្រសួងយុត្តិធម៌ និងលិខិតបញ្ជាក់ទីលំនៅ ឬលិខិតទទួលស្គាល់ពីម្ចាស់ក្រុមហ៊ុនអាជីវកម្ម។

ក្នុងឆ្នាំ២០០៩ ក្រសួងទេសចរណ៍បានផ្តល់អាជ្ញាប័ណ្ណជូនបុគ្គលប្រកបអាជីវកម្មទេសចរណ៍ ដូចជាក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍ សណ្ឋាគារ ម៉ាស្សា ខារ៉ាអូខេ ក្រុមហ៊ុនដឹកជញ្ជូនទេសចរណ៍ពុំមានភ្ជាប់មកជាមួយនូវឯកសារចាំបាច់មួយចំនួនដូចជា ប័ណ្ណប៉ាតង់ វិញ្ញាបនប័ត្រធានារ៉ាប់រង ឱ្យស្របតាមបទប្បញ្ញត្តិនៅឡើយ។

ការមិនផ្តល់ឯកសារភ្ជាប់គ្រប់គ្រាន់ នាំឱ្យការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍មិនទាន់ស្របនឹងគោលការណ៍។ អាស្រ័យដូចនេះ ក្រសួងទេសចរណ៍មិនត្រូវផ្តល់ ឬបន្តអាជ្ញាប័ណ្ណអាជីវកម្មទេសចរណ៍ ចំពោះបុគ្គលប្រកបអាជីវកម្ម ឬក្រុមហ៊ុនដែលពុំមានភ្ជាប់មកជាមួយនូវឯកសារគ្រប់គ្រាន់ស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបតាមការលើកឡើងខាងលើ ក្រសួងទេសចរណ៍បានបញ្ជាក់ថា ទន្ទឹមនឹងច្បាប់ស្តីពីទេសចរណ៍ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់រួចមក ក្រសួងទេសចរណ៍បានរៀបចំកែសម្រួលរាល់ប្រកាស សារាចរណែនាំនានា ឱ្យស្របទៅនឹងច្បាប់ស្តីពីទេសចរណ៍ ក្នុងនោះរួមមាន ប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណទេសចរណ៍ដល់សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយ-ដ្ឋាន ទីភ្នាក់ងារទេសចរណ៍ ម៉ាស្សា ខារ៉ាអូខេ នីស្កូតែក សេវាដឹកជញ្ជូនទេសចរណ៍ មគ្គុទ្ទេសទេសចរណ៍ និងកីឡាទេសចរណ៍។ល។ ជាទូទៅ ឯកសារគោលដែលមិនអាចខ្វះបាន គឺលិខិតបញ្ជាក់ទីតាំងពីអាជ្ញាធរដែនដី ដែលជាលក្ខខណ្ឌចាំបាច់ក្នុងការសម្រេចថា ត្រូវផ្តល់ ឬមិនផ្តល់អាជ្ញាប័ណ្ណទេសចរណ៍។ ដោយឡែកឯកសារនានាដូចជា ប័ណ្ណប៉ាតង់ និងប័ណ្ណធានារ៉ាប់រងជាដើម គឺជាកាតព្វកិច្ចផ្ទាល់របស់អាជីវករជាមួយស្ថាប័នអនុវត្តច្បាប់នានា។

អាជ្ញាធរសវនកម្មជាតិ នឹងបន្តពិនិត្យនូវវឌ្ឍនភាព។

**៣.១.៦.ការត្រួតពិនិត្យភាពប្រាកដប្រជានៃចំណាយថវិការដ្ឋ**

អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ត្រង់មាត្រា១៣ បានចែងថា "ក្នុងវិស័យ

ចំណាយត្រូវត្រួតពិនិត្យការបញ្ជាក់ត្រឹមត្រូវអំពីសេវាដែលបានធ្វើហើយ និងភាពប្រាកដប្រជានៃគណនាជំរះឥណទេយ្យ (បំណុល)"។ ក្នុងការអនុវត្តជាក់ស្តែង នាយកដ្ឋានមួយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានស្នើសុំបំពេញចំណាយឡើងវិញពុំទាន់ត្រឹមត្រូវតាមគោលការណ៍ហិរញ្ញវត្ថុ ដោយបុគ្គលដកសាច់ប្រាក់យកទៅចំណាយផ្ទាល់ខ្លួនចំនួន៥០៧.០៨៣ ដុល្លារអាមេរិក និងការចំណាយមួយចំនួនទៀតពុំមានឯកសារបញ្ជាក់ (សក្ខីប័ត្រ) អំពីភាពត្រឹមត្រូវលើសេវាដែលបានធ្វើចំនួន ១៩៣.៩៥៨ ដុល្លារអាមេរិក។

ការមិនបានត្រួតពិនិត្យពេញលេញ លើឯកសារចំណាយនាំឱ្យមានហានិភ័យបាត់បង់សាច់ប្រាក់។ អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរធ្វើការណែនាំដល់អង្គភាពក្រោមឱវាទឱ្យចាត់វិធានការលើករណីនេះ ដោយឱ្យបង់ប្រាក់ខាងលើចូលថវិការដ្ឋវិញឱ្យបានឆាប់រហ័ស និងត្រូវអនុវត្តមាត្រា១៣ នៃអនុក្រឹត្យលេខ៨២ ឱ្យបានម៉ឺងម៉ាត់។

ចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ជាក់ថា កង្វះខាតការត្រួតពិនិត្យភាពប្រាកដប្រជានៃចំណាយថវិការដ្ឋនេះគឺ បណ្តាលមកពីយន្តការរួមនៃការត្រួតពិនិត្យចំណាយនៅមានភាពខ្វះចន្លោះ ដែលជាឱកាសផ្តល់ឱ្យមន្ត្រីខិលខូចអាចឆ្លៀតឱកាសកេងបន្លំថវិការដ្ឋបាន។ ឆ្លើយតបទៅនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចាត់វិធានការកែតម្រូវលើយន្តការនៃការត្រួតពិនិត្យចំណាយដែលនៅមានភាពខ្វះចន្លោះនេះជាបន្ទាន់ ព្រមទាំងបានបញ្ជូនមន្ត្រីដែលបានប្រព្រឹត្តកំហុសឆ្គងនោះទៅស្ថាប័នតុលាការ ដើម្បីដោះស្រាយទៅតាមផ្លូវច្បាប់រួចរាល់ហើយ។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិសូមវាយតម្លៃខ្ពស់ចំពោះស្មារតីយកចិត្តទុកដាក់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការចាត់វិធានការ និងស្នើក្រសួងបន្តតាមដានលើករណីនេះបន្តទៀត។

**៣.១.៧.ការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ**

សារាចរលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់ បានចែងថា "ត្រូវវិភាគ និងកំណត់រយៈពេលគ្រប់ដំណាក់កាលក្នុងដំណើរការលទ្ធកម្មដែលទាក់ទងនឹងគម្រោងនីមួយៗ..."។

នាយកដ្ឋានលទ្ធកម្មសាធារណៈ បានចូលរួមប្រគល់ទទួលការងារលើគម្រោងមួយចំនួន ដែលមាន រយៈពេលអនុវត្តឃ្លាតឆ្ងាយពេកពីរយៈពេលវេលានៃការអនុវត្តកិច្ចសន្យា ឯកសារដេញថ្លៃ និងតារាងពេលវេលានៃការអនុវត្តគម្រោងនីមួយៗ។

ចំពោះការអនុវត្តនេះ អាចប៉ះពាល់ដល់គុណភាពសំណង់ ឬអាចពុំទាន់សមស្របតាមភាពជាក់ស្តែង។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរធ្វើការណែនាំដល់អង្គភាពក្រោមឱវាទដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធអនុវត្តឱ្យបានត្រឹមត្រូវតាមបទបញ្ញានានាពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈ ដើម្បីធានានូវតម្លាភាព និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានមតិថា ការងារស្ថាបនាផុសផុលសុទ្ធតែត្រូវបានអនុវត្តរួចរាល់តាមកិច្ចសន្យាដោយ "ភាគីអ្នក

ទទួលការៈ បានចាប់ផ្តើមដំណើរការអនុវត្តការងារ នៅពេលទទួលបានគោលការណ៍អនុញ្ញាត ឱ្យអនុវត្តវិធីសាស្ត្រលទ្ធកម្មចុះកិច្ចសន្យាផ្ទាល់ ហើយបានពន្លឿនការងារឱ្យបានរួចរាល់ដើម្បីរៀបចំបែបបទទូទាត់ឱ្យបានមុនការបិទការិយបរិច្ឆេទឆ្នាំអនុវត្តថវិកា។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិសូមឱ្យនាយកដ្ឋានលទ្ធកម្មសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុវត្តតាមសារាចរខាងលើ ដើម្បីជៀសវាងការអនុវត្តការងារខុសនឹងកិច្ចសន្យា ឯកសារដេញថ្លៃ និងតារាងពេលវេលាសម្រាប់គម្រោងនីមួយៗ។

### ៣.១.៨.ការវាយតម្លៃលើប្រភពធនធានទ្រព្យសម្បត្តិរដ្ឋ

ប្រកាសលេខ១៨០២ សហវ.ប្រក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យអនុវត្តប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋ បានតម្រូវឱ្យរតនាគារជាតិធ្វើសមាហរណកម្ម (ការរួមបញ្ចូលគ្នា) បំណុលដើម្បីកត់ត្រាចំនួនទឹកប្រាក់ជាប្រភពធនធានរបស់រដ្ឋ និងបំណុលត្រូវសង ត្រូវទារ ដែលកន្លងមកពុំទាន់បានកត់ត្រាទៅក្នុងលេខនៃគណនេយ្យ។ តម្លៃនៃទ្រព្យសម្បត្តិ និងបំណុលទាំងនេះ គឺបានមកពីការវាយតម្លៃនៅលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពដែលមានការពាក់ព័ន្ធ។

ក្នុងឆ្នាំ២០០៩នេះ អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា អគ្គនាយកដ្ឋានរតនាគារជាតិ បានប្រមូលផ្តុំបំណុលត្រូវសងមួយចំនួន ប៉ុន្តែពុំទាន់បានវាយតម្លៃលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីកត់ត្រាជាធនធានរបស់រដ្ឋក្នុងកិច្ចបញ្ជីគណនេយ្យឱ្យស្របតាមប្លង់គណនេយ្យទូទៅនៃគណនេយ្យរដ្ឋនៅឡើយ។

ដើម្បីពង្រឹងការគ្រប់គ្រងការកត់ត្រាប្រភពធនធាន នៃតម្លៃទ្រព្យសម្បត្តិឱ្យបានត្រឹមត្រូវ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអង្គភាពក្រោមនិវាទ ឱ្យធ្វើការវាយតម្លៃលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពដែលមានការពាក់ព័ន្ធ ដើម្បីកត់ត្រាតាមដានទ្រព្យសម្បត្តិឱ្យបានច្បាស់លាស់ស្របតាមខ្លឹមសារនៃប្រកាសខាងលើ។

**៣.១.៩.ការអនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈ**

សារាចរលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់ បានកំណត់ថាសម្រាប់ទឹកប្រាក់ក្រោម២០លានរៀល អនុវត្តវិធីសាស្ត្រស្ទង់តម្លៃ ទឹកប្រាក់ចាប់ពី២០លានរៀលដល់ក្រោម១០០លានរៀល អនុវត្តវិធីសាស្ត្រពិគ្រោះថ្លៃ ចាប់ពី១០០លានរៀល ដល់ក្រោម ១.០០០លានរៀល អនុវត្តវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក និងទឹកប្រាក់ចាប់ពី ១.០០០លានរៀលឡើង អនុវត្តការដេញថ្លៃដោយវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ។ ប៉ុន្តែតាមការធ្វើសវនកម្មនៅកំពង់ផែស្វយ័តភ្នំពេញ សម្រាប់ការិយបរិច្ឆេទ ២០០៩ ឃើញថាមានកិច្ចលទ្ធកម្មចំនួន០៩ អនុវត្តវិធីសាស្ត្រលទ្ធកម្មមិនស្របទៅនឹងការកំណត់ នៃការអនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈ។

អាស្រ័យហេតុនេះ ដើម្បីអនុវត្តតាមវិធីសាស្ត្រលទ្ធកម្មសមស្រប កំពង់ផែស្វយ័តភ្នំពេញគួរអនុវត្តឱ្យបានត្រឹមត្រូវតាមសារាចរខាងលើ។

ជាការឆ្លើយតបនឹងការលើកឡើងខាងលើ កំពង់ផែស្វយ័តភ្នំពេញបានបំភ្លឺថា គ្រឿងចក្រមួយចំនួនដែលទិញ គឺជាផលិតផលជជុះ ហេតុនេះទើបមានគណៈកម្មការបច្ចេកទេសដើម្បីពិនិត្យជាក់ស្តែងលើឧបករណ៍គ្រឿងចក្រនោះ ព្រោះតម្លៃថោកមិនប្រាកដថាមានគុណភាពល្អ អាចប្រើប្រាស់បានយូរទេ។ ឯសម្ភារគ្រឿងចក្រខ្លះថ្មី ១០០ភាគរយ ដែលត្រូវទិញជាផលិតផលផ្តាច់មុខដែលពុំមានក្រុមហ៊ុនផ្សេងទៀតលក់នៅក្នុងស្រុក ដូចជារថយន្តជាដើម។

ផ្អែកលើការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិ សូមឱ្យកំពង់ផែស្វយ័តភ្នំពេញអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈដោយពិភាក្សាជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានលទ្ធកម្មសាធារណៈ) ឱ្យបានសមស្រប។

## ៣.២.ការគ្រប់គ្រងចំណូលរាជធានី ខេត្ត

### ៣.២.១.ការគ្រប់គ្រង និងការប្រមូលចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូន

ម្ចាស់យានយន្តគ្រប់ប្រភេទមានកាតព្វកិច្ចធ្វើការចុះបញ្ជី ឬធ្វើប័ណ្ណសម្គាល់យានយន្តនៅអង្គភាពជំនាញរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ហើយមានកាតព្វកិច្ចក្នុងការបង់ពន្ធមធ្យោបាយដឹកជញ្ជូនតាមប្រកាស ស្តីពីការប្រមូលចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូនប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីមានសិទ្ធិស្របច្បាប់ក្នុងការធ្វើចរាចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការធ្វើសវនកម្មលើស្ថិតិចុះបញ្ជីយានយន្តពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០០៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងស្ថិតិយានយន្តបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

សម្រាប់ឆ្នាំ២០០៩ របស់អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឃើញថា ការប្រមូលចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទពុំទាន់ពេញលេញនៅឡើយ ដោយឃើញមានរថយន្តគ្រប់ប្រភេទចំនួន៥៧.៩៥៩គ្រឿង ពុំបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងទោចក្រយានយន្តគ្រប់ប្រភេទចំនួន១១៧.២៣២គ្រឿង មិនបានចុះបញ្ជីនៅក្រសួងសាធារណការ និងដឹកជញ្ជូន ប៉ុន្តែឃើញមានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន។

ការមិនផ្លាស់ប្តូរព័ត៌មានឱ្យបានទាន់ពេលវេលា រវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងអគ្គនាយកដ្ឋានពន្ធដារ អាចនាំឱ្យការគ្រប់គ្រងយានយន្ត និងការប្រមូលពន្ធមធ្យោបាយដឹកជញ្ជូនពុំទាន់បានល្អប្រសើរ។ អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គួរធ្វើការណែនាំដល់អង្គភាពក្រោមឱវាទឱ្យសហការផ្លាស់ប្តូរព័ត៌មានជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពង្រឹងការគ្រប់គ្រង និងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូនបន្ថែមទៀត។

ករណីនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានមតិថា ក្រសួងបានណែនាំឱ្យអគ្គនាយកដ្ឋានពន្ធដារធ្វើការប្រជុំពិភាក្សាជាមួយក្រសួងសាធារណការ និងដឹកជញ្ជូនជាញឹកញាប់ ដើម្បីដោះស្រាយការងារបច្ចេកទេស និងស្ថិតិយានយន្តដែលចុះបញ្ជី។ ចំនួនយានយន្ត ដែលមានភាពលម្អៀងនេះ អាចបណ្តាលមកពីយានយន្តមួយចំនួនរងគ្រោះថ្នាក់ខូចខាតមិនអាចប្រើប្រាស់បាន ឬចាស់ពេកជួសជុលលែងកើត។ ករណីខ្លះទៀត អាចបណ្តាលមកពីការក្លែងបន្លំលតាបត្របង់ពន្ធ ហើយចំពោះករណីនេះ អគ្គនាយកដ្ឋានពន្ធដារបានសហការ

ជាមួយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីទប់ស្កាត់ជនឆ្លៀតឱកាស ដែលក្លែងបន្លំលតាបត្រូបង់ពន្ធទាំងនោះ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានលើកឡើងបន្ថែមថា ក្នុងឆ្នាំ២០១០ អគ្គនាយកដ្ឋានពន្ធដារបានអនុវត្តប្រមូលពន្ធលើយានយន្តបានលើសពីឆ្នាំ២០០៩ ប្រហែល២ ម៉ឺនគ្រឿង។

ជាងនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបញ្ជាក់បន្ថែមថា ពាក់ព័ន្ធនឹងការគ្រប់គ្រង និងការប្រមូលចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើលិខិតជូនក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីស្នើសុំកិច្ចសហការក្នុងការទទួលបានទិន្នន័យយានយន្តគ្រប់ប្រភេទដែលបានចុះបញ្ជីនៅក្រសួងសាធារណការ និងដឹកជញ្ជូន។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានពន្ធដារ កំពុងធ្វើការទំនាក់ទំនងបន្តទៀត ដើម្បីទទួលបាននូវទិន្នន័យដែលស្នើសុំ ក្នុងគោលបំណងពង្រឹងការគ្រប់គ្រង និងប្រមូលចំណូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទនេះ ឱ្យមានប្រសិទ្ធភាព។

ផ្អែកតាមការបំភ្លឺខាងលើ អាជ្ញាធរសវនកម្មជាតិ នឹងបន្តពិនិត្យនូវវឌ្ឍនភាព។

**៣.២.២.ការប្រមូលចំណូលពីសត្តឃាតដ្ឋាន**

ដើម្បីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធឱ្យមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចេញសារាចរលេខ ០១២ សហវ.សរ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការប្រមូលចំណូលលើទ្រព្យសម្បត្តិសាធារណៈ។ ក្រសួងបានតម្រូវឱ្យមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុដាក់ផ្តលទ្រព្យសម្បត្តិសាធារណៈដូចជា ផ្សារ កំពង់ផ ចំណតរថយន្ត ចំណតជលយាន

យៀត្រី និងសត្តឃាតដ្ឋាន។ល។ ដោយត្រូវប្រមូលផ្តុំដេញថ្លៃទាំងអស់នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរៀងរាល់អាណត្តិនីមួយៗ ក្រោមការដឹកនាំរបស់អភិបាលខេត្ត ក្រុង។ រីឯកំណាត់ហេតុដេញថ្លៃ និងសៀវភៅបន្ទុកភាស៊ីត្រូវមានការឯកភាពយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្នុងឆ្នាំ២០០៩ តាមការធ្វើសវនកម្មនៅរាជធានី និងខេត្តចំនួន០៧ ក្នុងនោះមានខេត្តចំនួន០២ បានអនុញ្ញាតឱ្យធ្វើអាជីវកម្មសត្តឃាតដ្ឋាន ដោយមិនមានការដេញថ្លៃជាសាធារណៈ និងមិនមានការឯកភាពយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឡើយ។

អាស្រ័យហេតុនេះ ដើម្បីធានាការដេញថ្លៃនៃសត្តឃាតដ្ឋានប្រកបដោយតម្លាភាព សាលាខេត្ត និងអង្គភាពពាក់ព័ន្ធគួររៀបចំលិខិតបទដ្ឋានតាមនីតិវិធី ហើយដាក់ទីសត្តឃាតដ្ឋានទាំងនោះ ឱ្យដេញថ្លៃជាសាធារណៈស្របតាមសារាចរខាងលើ។

ឆ្លើយតបនឹងការលើកឡើងខាងលើ សាលាខេត្តបានឯកភាព និងបានសន្យាជំរុញការអនុវត្តការងារនេះឱ្យបានឆាប់រហ័ស។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិរំពឹងថាការគ្រប់គ្រងប្រមូលចំណូលពីទីសត្តឃាតដ្ឋាននឹងអនុវត្តបានល្អប្រសើរនាពេលខាងមុខ។

**៣.២.៣.ចំណាត់ការលើការសាងសង់**

ដើម្បីគ្រប់គ្រងសំណង់ឱ្យបានល្អ រាជរដ្ឋាភិបាលបានដាក់ចេញនូវបទប្បញ្ញត្តិសម្រាប់ឱ្យអនុវត្តដោយតម្រូវឱ្យម្ចាស់សំណង់សុំលិខិតអនុញ្ញាតសាងសង់ពីស្ថាប័នមានសមត្ថកិច្ច

ជាមុន ក្នុងករណីមិនមានលិខិតអនុញ្ញាតសាងសង់ ស្ថាប័នមានសមត្ថកិច្ចត្រូវធ្វើការឃាត់ឃាំងការសាងសង់នោះមិនឱ្យបន្តសាងសង់ឡើយ។

ក្នុងឆ្នាំ២០០៩ តាមរយៈការធ្វើសវនកម្មនៅខេត្តចំនួន០២ ឃើញថា មានសំណង់ចំនួន៥៥ទីតាំង ដែលបានសាងសង់រួច ដោយពុំសុំលិខិតអនុញ្ញាត ហើយពុំឃើញមានស្ថាប័នមានសមត្ថកិច្ចធ្វើការទប់ស្កាត់លើការសាងសង់នោះឡើយ។

អាស្រ័យហេតុនេះ ដើម្បីធានាការសង់សំណង់ប្រកបដោយគុណភាពល្អ សោភ័ណភាព មានសុវត្ថិភាព និងទទួលបានចំណូលពីការចេញលិខិតអនុញ្ញាតសាងសង់ សាលាខេត្តត្រូវជំរុញមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ស្ថាប័នពាក់ព័ន្ធ ក្រុង ស្រុក ឃុំ សង្កាត់ ឱ្យអនុវត្តនូវតួនាទី និងភារកិច្ចរបស់ខ្លួនស្របតាមបទប្បញ្ញត្តិ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ សាលាខេត្ត និងមន្ទីរសន្យាថា នឹងខិតខំជំរុញអង្គភាពជំនាញក្រោមឱវាទឱ្យខិតខំកែលម្អនូវកង្វះខាតឱ្យមានភាពល្អប្រសើរថែមទៀត។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថាការងារនេះនឹងអនុវត្តបានល្អប្រសើរនាពេលខាងមុខ។

### ៣.២.៤.ការគ្រប់គ្រងប្រើប្រាស់ប័ណ្ណភាសី

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានតួនាទី និងភារកិច្ចធ្វើជាសេនាធិការឱ្យសាលាខេត្ត និងរាជធានីក្នុងការគ្រប់គ្រងប្រមូលចំណូលភាសីគ្រប់ប្រភេទបង់ចូលថវិកាខេត្ត និងរាជធានី។ តាមលក្ខខណ្ឌនៃសៀវភៅបន្ទុកភាសីបញ្ជាក់ថា ប័ណ្ណភាសីត្រូវកំណត់ និងចេញដោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ហាមយកប័ណ្ណនេះ

ទៅថតចម្លង ឬបោះពុម្ពដោយគ្មានការអនុញ្ញាត និងលក់បន្ត ប្រើប្រាស់ខុសមុខសញ្ញា ឬប្រើប្រាស់ច្រើនដង (ប័ណ្ណមួយសន្លឹកប្រើបានតែមួយលើក)។ តាមការសង្កេតជាក់ស្តែង អាជីវករដែលទទួលសិទ្ធិទារភាស៊ីគ្រប់ប្រភេទមិនបានអនុវត្តតាមសៀវភៅបន្ទុកក្នុងការទិញប័ណ្ណភាស៊ីពីមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុទេ គឺពួកគាត់បានបោះប័ណ្ណភាស៊ីនេះ ដោយខ្លួនឯង។

អាស្រ័យហេតុនេះ ដើម្បីពង្រឹងការប្រមូលចំណូលភាស៊ីផ្សារឱ្យបានត្រឹមត្រូវ និងមានតម្លាភាព សាលាខេត្តគួរជំរុញមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមកិច្ចសន្យា និងសៀវភៅបន្ទុក។

ឆ្លើយតបនឹងការលើកឡើងខាងលើ សាលាខេត្តបានបំភ្លឺថា ការងារនេះមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការប្រជុំពិភាក្សា និងកែសម្រួលនូវរាល់ចំណុចខ្វះខាតបានត្រឹមត្រូវហើយ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនឹងបន្តពិនិត្យនូវវឌ្ឍនភាព។

## ៣.៣.ការអនុវត្តគម្រោងវិនិយោគ

### ៣.៣.១.ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ចាប់ពីឆ្នាំ២០០៥ រហូតដល់ឆ្នាំ២០០៩ អង្គភាពគ្រប់គ្រងគម្រោងបានរៀបចំនូវរបាយការណ៍អំពីវឌ្ឍនភាពរបស់គម្រោងប្រចាំខែ ត្រីមាស និងឆ្នាំផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលរបាយការណ៍ទាំងនោះ ឆ្លុះបញ្ចាំងតែចំណុចមួយចំនួនដូចជា សេចក្តីសង្ខេបប្រាក់កម្ចី វិសាលភាពគម្រោង លទ្ធផល

ការងារសម្រេចបាន ការតាមដានបំណុល ការប្រើប្រាស់ថវិកាបដិភាគ ការចំណាយ លើការបង់ពន្ធប៉ុណ្ណោះ ហើយក្នុងនោះ អង្គភាពគ្រប់គ្រងគម្រោងខ្លះពុំទាន់បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យស្របតាមគោលការណ៍គណនេយ្យនៃកិច្ចព្រមព្រៀងកម្ចីបន្តនោះទេ។ អាស្រ័យហេតុនេះ ដើម្បីឱ្យស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង អង្គភាពគ្រប់គ្រងគម្រោងទាំងនោះ គួរតែរៀបចំនូវរបាយការណ៍ហិរញ្ញវត្ថុគម្រោងឱ្យបានត្រឹមត្រូវស្របតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង។

ឆ្លើយតបនឹងការលើកឡើងខាងលើ អង្គភាពគ្រប់គ្រងគម្រោង បានឯកភាពតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិ។ អង្គភាពគ្រប់គ្រងគម្រោង ក៏បានបញ្ជាក់បន្ថែមថា អង្គភាពមានភារកិច្ច សម្របសម្រួល ត្រួតពិនិត្យ និងតាមដានរាល់ដំណើរការអនុវត្តគម្រោង និងការគ្រប់គ្រងបំណុល ប្រាក់កម្ចីពីបរទេស។ លើសពីនេះទៀត ការទូទាត់ចំណាយទាំងអស់ត្រូវធ្វើឡើងនៅប្រទេសម្ចាស់បំណុល ដោយមានការឯកភាពជាមុនពីធនាគារ។ ដោយសារតែការទទួលខុសត្រូវពុំមានលក្ខណៈពេញលេញនោះ អង្គភាពគ្រប់គ្រងគម្រោងនោះយល់ឃើញថា ពុំចាំបាច់ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុទេ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិសូមរំឭកថា ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះគឺសម្រាប់ផ្តល់នូវតម្លាភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រាក់កម្ចី និងការតាមដានរាល់ប្រតិបត្តិការហិរញ្ញវត្ថុរបស់គម្រោង។ ដូចនេះ អង្គភាពគួរតែរៀបចំនូវរបាយការណ៍ហិរញ្ញវត្ថុរបស់គម្រោងឱ្យស្របតាមគោលការណ៍គណនេយ្យ ជាក់លាក់ណាមួយ ដូចមានចែងក្នុងលក្ខខណ្ឌនៃកិច្ចព្រមព្រៀង។

## ៤.ការពិនិត្យនៅលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មនាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា រាល់ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មទាំងឡាយ ដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើងជាបន្តបន្ទាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងារ របស់បណ្តាក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា មានចំណុចខ្វះខាតមួយចំនួន ត្រូវបានកែលម្អគួរឱ្យកត់សម្គាល់ និងកោតសរសើរ។ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមានជាអាទិ៍៖

៤.១. ភាពយឺតយ៉ាវក្នុងការជម្រះផ្ទេរចំណូល ដែលផ្ទុយគោលការណ៍ហិរញ្ញវត្ថុ តាមមាត្រា១៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ កំណត់ថា "ចំណូលត្រូវកត់ត្រាចូលទាំងស្រុង ហើយមិនត្រូវយកទៅកាត់កងដោយត្រង់ជាមួយចំណាយឡើយ"។ ប្រកាសណែនាំលេខ៩៤៩ សហវ.ប្រក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូល ចំណាយ និងការធ្វើរបាយការណ៍បូកសរុបទូទាត់ចំណូល ចំណាយថវិការដ្ឋឆ្នាំ២០០៩ ត្រង់ចំណុច I-ក បានចែងថា "ចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកយកទៅចំណាយតាមទំនើងចិត្ត ឬមួយពន្យារបង់ចូលថវិការដ្ឋ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ។ ដូចនេះ ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិការដ្ឋយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ ជាកំហិត"។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មកន្លងមកឃើញថា អង្គភាពប្រតិបត្តិចំណូលមួយចំនួនដូចជា អគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងសាខាពន្ធដារខណ្ឌនៃរាជធានីភ្នំពេញ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ តែងតែដកចំណូល យកទៅចំណាយជារង្វាន់លើកទឹកចិត្ត និងចំណាយផ្សេងៗ មុនការបង់ចូលថវិការដ្ឋពុំទាន់បានធ្វើការជំរះផ្ទេរចំណូល និងពុំមានការកត់ត្រាចូលក្នុងថវិកានោះទេ។

៤.២. ការតាមដានការប្រើប្រាស់ទំនិញនាំចូលក្រោមរបបអនុគ្រោះពន្ធ ជាភារកិច្ចរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ដែលត្រូវតាមដានសម្ភារ បរិក្ខារ និងទំនិញគ្រប់ប្រភេទដែលទទួលបានការអនុគ្រោះនានា តាមទិសដៅដែលបានកំណត់ ត្រួតពិនិត្យការប្រើប្រាស់ដោយរួមទាំងការចុះទៅបំពេញភារកិច្ចតាមដាន និងឃ្លាំមើលជាអចិន្ត្រៃយ៍ ឬលក្ខណៈម្តងម្កាលតាមបណ្តាអាជីវកម្មដ្ឋាន ឬពាណិជ្ជកម្មនានាស្របតាមនីតិវិធីច្បាប់ជាធរមាន...។ ករណីនេះ អាជ្ញាធរសវនកម្មជាតិធ្លាប់បានផ្តល់អនុសាសន៍កន្លងមកហើយ ប៉ុន្តែនៅតែពុំឃើញមានឯកសាររបាយការណ៍ និងកំណត់ហេតុដែលបញ្ជាក់ថា នាយកដ្ឋានរដ្ឋាករ និងរបបគយនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាបានធ្វើការត្រួតពិនិត្យតាមដានលើការប្រើប្រាស់សម្ភារ បរិក្ខារ និងវត្ថុធាតុដើមដែលបាននាំចូលដោយពន្ធ និងអាករជាបន្ទុករបស់រដ្ឋនោះនៅឡើយ។

៤.៣. វិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញ គឺជាឯកសារសំខាន់មួយបញ្ជាក់អំពីថ្លៃ អត្តសញ្ញាណ និងគោលដៅនៃទំនិញ ហើយត្រូវបានក្រុមហ៊ុន អាជីវករ ឬអ្នកជំនួញទាំងឡាយប្រើប្រាស់ជាផ្លូវការ សម្រាប់

ការនាំចេញ នាំចូលទំនិញគ្រប់ប្រភេទ។ ប៉ុន្តែតាមការធ្វើសវនកម្ម កន្លងមកឃើញថា វិក្កយបត្រ និងបញ្ជីវេចខ្ចប់ទំនិញដែលបានយកមកប្រើប្រាស់ទាំងនោះ ភាគច្រើនជាឯកសារដែលបង្កើតឡើងដោយក្រុមហ៊ុន ឬបុគ្គលនាំចូលខ្លួនឯង ជាឯកសារពុំទាន់អាចបញ្ជាក់បាននូវភាពជាក់ស្តែងនៃថ្លៃទំនិញ។ ករណីនេះ អាជ្ញាធរសវនកម្មជាតិធ្លាប់បានផ្តល់អនុសាសន៍ រួចមកហើយ (ការិយបរិច្ឆេទ២០០២, ២០០៦, ២០០៧ និង២០០៨) ដោយឡែកសម្រាប់ការិយបរិច្ឆេទ២០០៩ នេះ ក៏នៅមានការប្រើប្រាស់នៅឡើយ។

៤.៤. ការគ្រប់គ្រង និងការកសាងបញ្ជីជំរឿនស្ថិតិអាជីវកម្មដ្ឋានជាសមត្ថកិច្ចគយ ដែលមានដែនដី ដែនទឹក ដែនអាកាស និងកោះនានានៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងឆ្នាំ២០០២ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ៣៦២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០២ ស្តីពីការបង្កើត និងដាក់ឱ្យដំណើរការនូវសាខាគយ និងរដ្ឋាករាជធានីភ្នំពេញ ត្រង់ប្រការ៣ ចំណុច៤ បានកំណត់ថា "សាខាគយ និងរដ្ឋាករាជធានីភ្នំពេញមានភារកិច្ចចុះស្រង់ និងកសាងបញ្ជីជំរឿនស្ថិតិអាជីវកម្មដ្ឋាន លក់ដុំ លក់រាយ ភណ្ឌាគារ សន្និធិទំនិញនានាដែលស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងពិសេសរួមមាន យានយន្តគ្រប់ប្រភេទ ផលិតផលតេលសិលា ភេសជ្ជៈ ព្រមទាំងទំនិញសេរីបមួយចំនួនទៀតដែលនឹងកំណត់ ដោយទីចាត់ការគយ និងរដ្ឋាករ"។ គិតត្រឹមឆ្នាំ ២០០៩ អាជ្ញាធរសវនកម្មជាតិនៅតែពុំឃើញមានឯកសារដែលបញ្ជាក់ថា សាខាគយ និងរដ្ឋាករាជធានីភ្នំពេញបានចុះស្រង់ និងកសាងបញ្ជីជំរឿនស្ថិតិអាជីវកម្មដ្ឋាន លក់ដុំ លក់រាយ ភណ្ឌាគារ សន្និធិទំនិញឱ្យ

ស្របទៅនឹងប្រកាសខាងលើនោះពេញលេញនៅឡើយ ដែលអាចនាំឱ្យការគ្រប់គ្រងមិនទាន់មានប្រសិទ្ធភាពខ្ពស់។

៤.៥. ការកត់ត្រាចំណូលថវិការដ្ឋតាមបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ នៅមិនទាន់បានកត់ត្រាពេញលេញដោយសារអាណាប័កក្រសួង ស្ថាប័ន ខេត្តមួយចំនួនមិនបានរៀបចំសលាកប័ត្រចំណូលចូលថវិការដ្ឋទៅអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីផ្ទៀងផ្ទាត់សម្រាប់កត់ត្រា។ ប៉ុន្តែអគ្គនាយកដ្ឋានរតនាគារជាតិបានកត់ត្រាចំណូលមិនមែនសារពើពន្ធចូលថវិការដ្ឋ ផ្អែកតាមប្រកាសឥណទាន ឬបង្កាន់ដៃបង់ប្រាក់ដែលបានបង់ចំណូលតាមរយៈធនាគារជាតិ (ចំណូលជារូបិយប័ណ្ណ) ដោយមិនឃើញមានភ្ជាប់សលាកប័ត្របង្វែរចំណូលចូលថវិការដ្ឋរបស់អាណាប័កក្រសួង ស្ថាប័ន ខេត្ត ក្រុងទេ ដែលជាហេតុនាំឱ្យចំណូលថវិការដ្ឋបង្ហាញពុំទាន់បានពេញលេញតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការដ្ឋ និងអាចបាត់ភាពទទួលខុសត្រូវរបស់អាណាប័កពាក់ព័ន្ធ។

៤.៦. ប្រកាសលេខ២៥៧ ប្រក.សហវ.គរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងលើទំនិញនាំចូលបានបញ្ជាក់ថា "ផលពីការលក់ទំនិញដែលនៅសល់ក្រោយពីការចំណាយផ្សេងៗ ត្រូវដាក់ក្នុងបេឡានៃនិក្ខិត្តភ័ណ្ឌ និងបញ្ញើ ត្រូវទុក២ឆ្នាំ ដើម្បីរង់ចាំម្ចាស់ទំនិញ ឬសិទ្ធិលាភទាំងឡាយ ហើយផុតរយៈពេលនេះ ត្រូវបានជាគុណប្រយោជន៍ដល់ថវិការដ្ឋ"។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករបានរក្សាទុកផលពីការលក់ទំនិញរឹបអូស និងលក់ទំនិញបាតឃ្លាំងផ្សេងៗ ផុតរយៈពេលកំណត់ ដោយពុំទាន់បង់ចូលថវិការដ្ឋនៅឡើយ។

៤.៧. ការរក្សាទុកសាច់ប្រាក់ក្នុងបេឡាលើសកម្រិតកំណត់ គឺមិនស្របនឹងប្រកាសលេខ ០១៤ ប្រក. សហវ.រជ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៩៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលបានកំណត់ចំនួនទឹកប្រាក់ចំណូលរបស់រដ្ឋដែលភ្នាក់ងារ ឬអង្គភាពប្រតិបត្តិនីមួយៗ អាចរក្សាទុកនៅក្នុងបេឡារបស់ខ្លួនត្រឹមចំនួនពី២លានរៀល ទៅ៥លានរៀលប៉ុណ្ណោះ។ ប៉ុន្តែផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មកន្លងមកឃើញថា នៅតាមបណ្តាទីស្នាក់ការគយ និងរដ្ឋាករខេត្តនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមួយចំនួន បានរក្សាទុកសាច់ប្រាក់ចំណូលក្នុងបេឡារបស់ខ្លួនមានរយៈពេលយូរថ្ងៃ ទើបបង់ចូលរតនាគារខេត្ត ដោយមូលហេតុនៃស្ថានភាពជាក់ស្តែងផ្សេងៗ។

៤.៨. កិច្ចសហការរវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា បានពង្រឹងជាបណ្តើរៗ ក្នុងនោះការកែសម្រួលសមាសភាពក្រុមការងាររបស់អគ្គនាយកដ្ឋានទាំងពីរ។ ថ្មីៗនេះ មានកិច្ចសហការរវាងអគ្គនាយកដ្ឋានទាំងពីរ ក្នុងការចាប់ឃាត់ទំនិញរបស់ក្រុមហ៊ុននាំចេញ-នាំចូល ដែលគេចវេសការបង់ពន្ធផ្ទៃក្នុង និងកំពុងដំណើរការនីតិវិធីនៅតុលាការផងដែរ។

៤.៩. ការបញ្ចូលមូលដ្ឋានអាជីវកម្មចូលរបបស្វ័យប្រកាស ត្រូវបានអនុវត្តចំពោះសហគ្រាសដែលបានទទួលធ្វើ ឬផ្គត់ផ្គង់អ្វីមួយ ឬក៏ច្រើនជូនអង្គការសាធារណៈ ហើយដែលចំនួនទឹកប្រាក់សរុបទាំងអស់ លើសពី១២៥.០០០.០០០រៀល ត្រូវស្ថិតក្នុងក្របខណ្ឌនៃការកំណត់ពន្ធតាមរបបពិតប្រាកដ ឬរបបស្វ័យប្រកាសដោយមិនគិតពីផលរបរប្រចាំឆ្នាំ។ តាមការធ្វើតេស្តនៅសាខាពន្ធដារខណ្ឌ ខេត្តមួយចំនួន ក្នុងឆ្នាំ២០០៩

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ៦២មូលដ្ឋានអាជីវកម្ម ដែលស្ថិតក្នុងរបបមៅការបានធ្វើការផ្គត់ផ្គង់ទំនិញ និងសេវាទៅឱ្យអង្គភាពរដ្ឋ ស្ថិតក្រោមផលរបរប្រចាំឆ្នាំសរុបនៃមូលដ្ឋានអាជីវកម្មនីមួយៗ លើសពី១២៥.០០០.០០០រៀល ដោយសាខាពន្ធដារមិនបានចាត់បញ្ចូលក្នុងក្របខណ្ឌនៃការកំណត់ពន្ធតាមរបបពិតឡើយ។

ការដែលមានអាជីវកម្មដ្ឋានមួយចំនួនជាប់ពន្ធតាមរបបមៅការ ហើយមានទំហំអាជីវកម្មធំ ដល់កម្រិតត្រូវបញ្ចូលក្នុងរបបស្វ័យប្រកាស ដោយសារសកម្មភាពអាជីវកម្មរបស់អាជីវកម្មដ្ឋានមានការកើនឡើងជាប្រចាំ ដែលការនេះតម្រូវឱ្យមានការគ្រប់គ្រង និងតាមដានជាប្រចាំផងដែរក្នុងការបញ្ចូលអាជីវកម្មដ្ឋានទាំងនោះក្នុងរបបស្វ័យប្រកាស។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំផែនការសកម្មភាពដើម្បីអនុវត្តតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចតេជោ នាយករដ្ឋមន្ត្រី** ក្នុងការបញ្ចូលក្រុមហ៊ុនក្នុងរបបស្វ័យប្រកាស។ ជាក់ស្ដែង គិតត្រឹមថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៩នេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាត់បញ្ចូលទៅក្នុងរបបស្វ័យប្រកាសនូវអាជីវកម្មដ្ឋានដែលមានផលរបរខ្ពស់ហើយជាប់ពន្ធរបបមៅការ បានចំនួន ១៥% នៃផែនការ ដែលស្មើនឹង១៤១ អាជីវកម្មដ្ឋាន (សម្រាប់សាខាពន្ធដារខណ្ឌនៃរាជធានី) និងចំនួន ២៩% នៃផែនការ ស្មើនឹង ៣២២ អាជីវកម្មដ្ឋាន (សម្រាប់សាខាពន្ធដារខេត្ត) ។ ព្រមជាមួយនេះ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក៏បានបង្កើតក្រុមការងារ ដើម្បីធ្វើការត្រួតពិនិត្យផលរបររបស់អាជីវកម្មដ្ឋាន ដើម្បីផ្ទេរទៅក្នុងរបបស្វ័យប្រកាសទៅតាម

បទប្បញ្ញត្តិដែលមានជាធរមាន ។ ការងារបញ្ចូលអាជីវកម្មដ្ឋានក្នុងរបបស្វ័យប្រកាសនេះ ត្រូវអនុវត្តជាប្រចាំ ។

៤.១០. ការមិនបានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់មុនឆ្នាំ២០១១។

ក្នុងករណីនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាននិងកំពុងរៀបចំតម្លៃមូលដ្ឋានគិតពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដោយធ្វើយ៉ាងណាឱ្យមានសង្គតិភាពជាមួយនឹងតម្លៃមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ ព្រមទាំងរៀបចំយន្តការក្នុងការពង្រឹងការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ តាមរយៈការឃាត់ទុក មិនអនុញ្ញាតឱ្យធ្វើការផ្ទេរកម្មសិទ្ធិនៅពេលមកបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ក្នុងករណីមិនបានបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់មុនឆ្នាំ២០១១។ ជាមួយនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កំពុងធ្វើការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីសុំទិន្នន័យពាក់ព័ន្ធផ្សេងៗ ដើម្បីធ្វើការពិនិត្យរៀបចំបញ្ជីដីត្រូវជាប់ពន្ធ និងពិនិត្យធ្វើបច្ចុប្បន្នកម្មសមាសភាពគណៈកម្មការ និងអនុគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់ ។

៤.១១. ការលើកលែងប្រាក់ពន្ធ និងប្រាក់ពន្ធបន្ថែមត្រូវបានកំណត់ក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុ។ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៤ បានកំណត់ថា ភាពយឺតយ៉ាវមិនបានបង់ពន្ធអាករនឹងអាចអនុគ្រោះ ពន្យារពេលបង់ពន្ធអាករ បន្ថយពន្ធអាករ ឬអាចរួចពន្ធអាករបាន តែក្នុងករណីមានមហន្តរាយដល់សកម្មភាពអាជីវកម្ម ឬទ្រព្យសម្បត្តិអ្នកជាប់ពន្ធអាករ ឬអាយុជីវិតរបស់អ្នកជាប់ពន្ធអាករ ហើយករណីចុងក្រោយរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គឺជាអ្នកសម្រេច។ ករណីនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើការណែនាំដល់គ្រប់សាខា

ពន្ធដារខេត្ត ខណ្ឌទាំងអស់ ព្រមទាំងនាយកដ្ឋានជំនាញពាក់ព័ន្ធទាំងអស់នៅថ្នាក់កណ្ដាល ដើម្បីធ្វើការប្រុងប្រយ័ត្នក្នុងការអនុវត្តនីតិវិធីក្នុងការលើកលែងប្រាក់ពន្ធ និងប្រាក់ពន្ធបន្ថែម ដោយត្រូវពិនិត្យឱ្យបានហ្មត់ចត់តាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

៤.១២. ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិត្រូវបានកំណត់និសានវាទត្រឹមវេលាម៉ោងដប់ប្រាំពីរ និងសាមសិបនាទីនាថ្ងៃទី២៩ ខែធ្នូ នៃឆ្នាំសារពើពន្ធ។ ប៉ុន្តែតាមការធ្វើសវនកម្ម កន្លងមកឃើញថា នៅតែមានការបញ្ជូនអាណត្តិបើកប្រាក់នេះ ក្រោយថ្ងៃនិសានវាទបិទបញ្ជីនៅឡើយ។

៤.១៣. ការអនុវត្តការងារលទ្ធកម្មសាធារណៈឱ្យបានល្អប្រសើរចាំបាច់រាល់កិច្ចលទ្ធកម្មត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមនីតិវិធី ដើម្បីធានាឱ្យកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅប្រកបដោយតម្លាភាព សមធម៌ និងការប្រកួតប្រជែងពេញលេញ។ ប៉ុន្តែតាមរយៈការធ្វើសវនកម្មលើរបាយការណ៍លទ្ធកម្មសាធារណៈលើទំនិញ សេវា និងសាងសង់ឆ្នាំ២០០៩ របស់ក្រសួង ស្ថាប័ននានា បានបង្ហាញឱ្យឃើញថា មាន១១ ករណីក្នុងចំណោម៣៦៩ ករណី អនុវត្តមិនបានពេញលេញតាមវិធីសាស្ត្រលទ្ធកម្មសាធារណៈ។

៤.១៤. ដើម្បីធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឱ្យបានត្រឹមត្រូវក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចេញសារាចរណែនាំលេខ០០១ សហវ.ទរ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៥ ស្ដីពីការកែសម្រួលធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយតម្រូវឱ្យគ្រប់ក្រសួង ស្ថាប័ន និងខេត្តក្រុង ធ្វើបញ្ជីសារពើភ័ណ្ឌលម្អិតសម្រាប់ឆ្នាំ២០០៤ ឱ្យបានជាដាច់ខាត

ដើម្បីទុកជាឆ្នាំគោលសម្រាប់ការប្រៀបធៀបបញ្ជីសារពើភ័ណ្ឌឆ្នាំ២០០៥ និងនៅបណ្តាឆ្នាំចន្លោះ០៥ឆ្នាំ ស្តីពីការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែ ការធ្វើសវនកម្មរយៈពេលកន្លងមកនេះ បានរកឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនពុំទាន់បានអនុវត្តឱ្យបានពេញលេញតាមសារាចរណែនាំខាងលើនេះទេ។ ជាក់ស្តែង រហូតមកដល់ឆ្នាំ២០០៩ អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនមិនបានធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតារាងប្រៀបធៀបការកើន/ថយ នៃទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០០៩ និងបញ្ជីសារពើភ័ណ្ឌលម្អិតឆ្នាំ២០០៩ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទាន់ពេលវេលានៅឡើយ។

៤.១៥. ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ដែលជាមូលដ្ឋានសំខាន់ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតលេខ៥៣០១ សហវ.ទរ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៣ ឱ្យក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងខេត្ត ក្រុង ធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើអចលនទ្រព្យឱ្យបានឆាប់រហ័ស និងបានចេញលិខិតលេខ៣៨៤៤ សហវ.ទរ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ រំលឹកអំពីការធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ។ ប៉ុន្តែ ការធ្វើសវនកម្មក្នុងឆ្នាំ២០០៩ បានបង្ហាញឱ្យឃើញថា ក្រសួង ស្ថាប័ន សាលាខេត្ត-រាជធានី និងមន្ទីរមួយចំនួនពុំទាន់ធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើអចលនទ្រព្យឱ្យបានគ្រប់ចំនួន និងទាន់ពេលវេលានៅឡើយ។

## ៥.សេចក្តីសន្និដ្ឋាន

ឆ្នាំ២០០៩ ជាឆ្នាំដ៏លំបាកបំផុតសម្រាប់ប្រទេសកម្ពុជា។ កម្ពុជាត្រូវរងផលប៉ះពាល់ព្រមៗគ្នាពីកលិយុគហិរញ្ញវត្ថុអន្តរជាតិ និងការធ្លាក់ចុះនៃ

សេដ្ឋកិច្ចសកលលោក ព្រមទាំងត្រូវបង្កើនចំណាយថវិកាយ៉ាងគំហុក ដើម្បីពង្រឹងនៀនការពារអធិបតេយ្យភាព និងបូរណភាពទឹកដី។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាមានភាពប៉ិនប្រសប់ ឈ្លាសវៃ ដឹកនាំនាវាកម្ពុជា ឆ្លងផុតពីគ្រោះកំណាចទាំងនោះដោយជោគជ័យ។ ជាក់ស្ដែង ចំណូល ថវិកាបានប្រហាក់ប្រហែលនឹងឆ្នាំ២០០៨ កំណើនសេដ្ឋកិច្ចមានភាព វិជ្ជមាន។ លទ្ធផលនេះ សបញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលមិនត្រឹមតែ អាចគ្រប់គ្រងសភាពការណ៍ម៉ាក្រូសេដ្ឋកិច្ចបានប៉ុណ្ណោះទេ ប៉ុន្តែថែម ទាំងអាចជំរុញឱ្យការអនុវត្តច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០០៩ សម្រេចបានជោគជ័យថែមទៀតផង។ ព្រមជាមួយនោះ រាជរដ្ឋាភិបាលក៏បានចាប់ផ្ដើមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ គឺគណនេយ្យភាពហិរញ្ញវត្ថុ ដែល មានគោលដៅសម្រេចឱ្យបាននូវគណនេយ្យភាព តម្លាភាព និងប្រសិទ្ធ ភាពខ្ពស់ក្នុងការប្រើប្រាស់ថវិកា ក្នុងការផ្ដល់សេវាសាធារណៈ ការរក្សា គុណភាព និងសង្គតភាពជាមួយនយោបាយផ្សេងទៀត។

ទោះបីជាយ៉ាងណាក៏ដោយ ការធ្វើសវនកម្មក៏បានរកឃើញនូវបញ្ហា មួយចំនួននៅតែបន្តកើតមាននៅក្នុងការគ្រប់គ្រងថវិកាទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ ដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀត ដើម្បីចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅ និងទូលំទូលាយ ពង្រឹង អភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាល ទី២ របស់រាជរដ្ឋាភិបាល។

ទន្ទឹមនឹងនេះផងដែរ របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ ការិយបរិច្ឆេទ២០០៩ លេខ៤នេះ នឹងរួមចំណែកជួយ

ដល់ការពង្រឹងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី២។ ជាងនេះទៀត អាជ្ញាធរសវនកម្មជាតិរង់ចាំទទួល ដោយក្តីគោរពនូវការចូលរួមយោបល់ពីសាធារណជន ក្នុងបុព្វហេតុពង្រឹងស្ថាប័ន អភិវឌ្ឍន៍ធនធានមនុស្ស និងភាពប្រសើរឡើងនូវគុណភាពនៃរបាយការណ៍សវនកម្ម៕